# គណៈកម្មការទ្រទ្រង់សាលារៀនរៃអង្គាសប្រាក់ កែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងធ្វើគំរូសម្រាប់ស្ត្រីផ្សេងទៀត

ទោះបីជាទើបបានធ្វើសមាជិកគណៈកម្មការទ្រទ្រង់សាលារៀនក្នុងរយៈពេលតែមួយឆ្នាំក៏ដោយ ក៏ស្ត្រីវ័យ ៤៩ឆ្នាំ ប៉ោ ឡេ ដែលមកពីភូមិ ពូហ្យាម រួមទាំងសហការីរបស់គាត់ សម្រេចបានជោគជ័យជាច្រើនក្នុងរយៈពេល ១២ខែកន្លងទៅនេះ។

ស្ត្រីជនជាតិព្នងរូបនេះ បានសម្រេចចិត្តធ្វើជាសមាជិកគណៈកម្មការទ្រទ្រង់រៀន ដោយសារមូលហេតុចំនួន២។ ទីមួយគឺគាត់មានចិត្តស្រលាញ់ការអប់រំខ្លាំង និងទីពីរគឺ គាត់ចង់ធ្វើគំរូសម្រាប់ស្ត្រី និងកុមារីផ្សេងទៀតក្នុងសហគមន៍របស់គាត់។

ឡេ ជាសមាជិកភេទស្រីម្នាក់ក្នុងចំណោមសមាជិកភេទស្រីចំនួនពីរនាក់ក្នុងជួរគណៈកម្មការទ្រទ្រង់សាលារៀន ដែលមានសមាជិក៨នាក់និយាយថា ៖ "ខ្ញុំចូលរួមក្នុងគណៈកម្មការទ្រទ្រង់សាលារៀន ព្រោះខ្ញុំចង់ធ្វើបុគ្គលគំរូសម្រាប់ស្ត្រីផ្សេងទៀតនៅក្នុងភូមិ។ ខ្ញុំចង់បង្ហាញពួកគេថា យើងក៏អាចធ្វើវាបានដែរ"។

ចាប់តាំងពីគណៈកម្មការមានភាពសកម្ម បន្ទាប់ពីបានរៀនអំពីតួនាទីគាត់និយាយថា ទំនាក់ទំនងរវាងសាលារៀន និងសហគមន៍មានការកែលម្អច្រើនបានលឿន និងបានធ្វើឱ្យគណៈកម្មការចូលរួមសកម្មក្នុងផែនការអភិវឌ្ឍន៍សាលារៀន។

អង្គការឃែរកម្ពុជាបាននិងកំពុងជួយគាំទ្រសាលាបឋមសិក្សា ពូហ្យាម តាមរយៈសិក្ខាសាលាបណ្តុះបណ្តាលនានាដែលនិយាយលម្អិតអំពីតួនាទីរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា។ ក្នុងផ្នែកមួយនៃសិក្ខាសាលាទាំងនេះ សមាជិកគណៈកម្មការត្រូវបានបង្រៀនថា ពួកគេគួរចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍន៍សាលារៀន រៃអង្គាសប្រាក់ និងក្នុងការសាងសង់សាលារៀន។

គាត់បញ្ជាក់ថា ៖ "នេះជារបៀបដែលនាំឱ្យមានគំនិតធ្វើរបងព័ទ្ធជុំវិញសាលារៀន"។

គាត់រៀបរាប់ថា ៖ "យើងបានពិគ្រោះជាមួយសហគមន៍ ហើយយើងទាំងអស់គ្នាបានសម្រេចចិត្តថា យើងចង់ធ្វើរបងព័ទ្ធជុំវិញសាលារៀន"។

បន្ទាប់ពីបានធ្វើការសម្រេចចិត្ត សមាជិកគណៈកម្មការទ្រទ្រង់សាលារៀនបានចុះទៅតំបន់គោលដៅរបស់ខ្លួនដើម្បីរៃអង្គាសប្រាក់ធ្វើរបង។ ភូមិនេះត្រូវបានបែងចែកជាតំបន់គោលដៅចំនួន៨ ដោយសមាជិកម្នាក់ៗទទួលខុសត្រូវតំបន់គោលដៅរៀងៗខ្លួន។



© Nicolas Axelrod / Ruom / CARE

*"ខ្ញុំចូលរួមក្នុងគណៈកម្មការទ្រទ្រង់សាលារៀន ព្រោះខ្ញុំចង់ធ្វើបុគ្គលគំរូសម្រាប់ស្ត្រីផ្សេងទៀតនៅក្នុងភូមិ។ ខ្ញុំចង់បង្ហាញពួកគេថា យើងក៏អាចធ្វើវាបានដែរ"។*

គាត់និយាយដោយមោទនភាពថា ៖ "ខ្ញុំពិតជាភ្ញាក់ផ្អើលចំពោះចំនួនប្រាក់ដែលយើងរៃអង្គាសបាន ពីសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល។ យើងរៃប្រាក់បាន១លានរៀល (២៥០ដុល្លារសហរដ្ឋអាមេរិក) ដើម្បីទិញបង្គោលរបងយកមកដាំជុំវិញសាលារៀន និងដើម្បីយើងអាចធ្វើសួនបាន"។

ការប្តេជ្ញាចិត្ត និងការដឹកនាំរបស់ឡេបង្ហាញថា ការចូលរួមពីអ្នកទាំងឡាយក្នុងសហគមន៍នៅក្នុងអភិបាលកិច្ចសេវាមូលដ្ឋានរបស់ពួកគាត់អាចមានផលដ៏វិជ្ជមានលើអ្វីដែលសហគមន៍អាចសម្រេចបាន។

---

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

សហភាពអឺរ៉ុប SWEDEN unicef

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

*© CARE Cambodia, September 2016*